Disability Rights California

*ប្រព័ន្ធការពារ និងតស៊ូមតិរបស់រដ្ឋកាលីហ្វ័រនីញ៉ា*

# *បណ្តឹងផ្នែកកំហុសស៊ីវិល -- ការដាក់ពាក្យប្តឹងប្រឆាំងនឹងអង្គភាពរដ្ឋ ក្រោមច្បាប់បណ្តឹងកំហុសស៊ីវិលរដ្ឋកាលីហ្វ័រនីញ៉ា*

*ឯកសារបោះពុម្ពផ្សាយប្រចាំខែកុម្ភៈ ឆ្នាំ 2019 លេខ 5229.06*

បើអ្នកគិតថាអ្នកបានរងការឈឺចាប់ ហើយចង់ដាក់ពាក្យប្តឹងតាមផ្លូវច្បាប់ ដោយសាររបួសស្នាមលើរាងកាយ ជាបឋមអ្នកត្រូវដាក់ពាក្យប្តឹងកំហុសស៊ីវិល ជាមុនសិន ។

បណ្តឹងផ្នែកកំហុសស៊ីវិល គឺជាសំណុំរឿងដែលអ្នកដាក់ប្តឹង ប្រសិនបើជនបង្ករបួសស្នាមលើរាងកាយអ្នក គឺជាមន្ត្រីរដ្ឋការ ។ ជាធម្មតា អ្នកត្រូវដាក់ពាក្យប្តឹងផ្នែកកំហុសស៊ីវិល ក្នុងរវាង **ប្រាំមួយខែ** គិតចាប់ពីពេលដែលអ្នករងគ្រោះថ្នាក់ ។ បើអ្នកមិនបានដាក់ពាក្យប្តឹងផ្នែកកំហុសស៊ីវិលឲ្យបានទាន់ពេលទេ គឺអ្នកមិនអាចដាក់ពាក្យប្តឹងតាមផ្លូវច្បាប់បានឡើយ ។

បើអ្នកចង់ដាក់ពាក្យប្តឹងតាមផ្លូវច្បាប់ដោយសាររបួសស្នាមលើរាងកាយ គឺអ្នកត្រូវទាក់ទងមេធាវី ជាបន្ទាន់ ។ អង្គការ Disability Rights California មិនមានជំនាញឯកទេសក្នុងកិច្ចការច្បាប់ផ្នែកនេះឡើយ ។ យើងខ្ញុំមិនអាចផ្តល់ដំបូន្មានដល់អ្នកអំពីការដាក់ពាក្យប្តឹងផ្នែកកំហុសស៊ីវិលបានឡើយ ។ យើងខ្ញុំមិនអាចជួយអ្នក ដើម្បីដាក់ពាក្យប្តឹងផ្នែកកំហុសស៊ីវិលបានឡើយ ។

បើទោះបីជាបញ្ហានេះបានកើតឡើងលើសពីប្រាំមួយខែហើយក៏ដោយ ក៏អ្នកនៅតែគួរទាក់ទងមេធាវីផ្នែករបួសស្នាមលើរាងកាយដែរ ។ មេធាវីក្នុងផ្នែកនេះ អាចជួយប្រាប់អ្នកឲ្យប្រើសំណុំបែបបទត្រឹមត្រូវ លើបណ្តឹងកំហុសស៊ីវិល ជជែកជាមួយអ្នកអំពីពេលចាប់ផ្តើមនៃបន្ទាត់ពេលវេលារបស់អ្នក ហើយជួយអ្នកក្នុងការរកមើលថ្ងៃផុតកំណត់នៃពេលវេលារបស់អ្នក។ មេធាវីផ្នែកនេះ អាចប្រាប់អ្នកថាតើ អ្នកអាចដាក់ពាក្យប្តឹងយឺតបានដែរឬទេ ។ មេធាវីឯកទេសលើរបួសស្នាមលើរាងកាយ អាចជួយណែនាំអ្នកពីជំហានបន្ទាប់ដែលអ្នកត្រូវធ្វើ ក្រោយពេលអ្នកបានដាក់បណ្តឹងផ្នែកកំហុសស៊ីវិល រួចរាល់ ។

អង្គការ Disability Rights California អាចផ្តល់ឲ្យអ្នកនូវបញ្ជីឈ្មោះមេធាវីឯកទេសផ្នែករបួសស្នាមលើរាងកាយ ឬអ្នកអាចទូរស័ព្ទទៅកាន់សេវាកម្មផ្នែកបញ្ជូនកូនក្តី នៃសមាគមន៍មេធាវីរដ្ឋកាលីហ្វ័រនីញ៉ា ដើម្បីស្នើសុំការបញ្ជូនកូនក្តី តាមទូរស័ព្ទលេខ ៖

1-866-442-2529

www.calbar.org/lrs

យើងខ្ញុំចង់ស្តាប់យោបល់អ្នក! សូមជួយបំពេញសំណួរសម្រង់មតិខាងក្រោម ស្តីអំពីការបោះពុម្ពផ្សាយរបស់យើងខ្ញុំ
ហើយប្រាប់ឲ្យយើងខ្ញុំបានដឹងពីគុណភាពការងាររបស់យើងខ្ញុំ! [ចូលរួមការស្ទង់មតិ]

សម្រាប់ជំនួយផ្លូវច្បាប់ សូមហៅមកលេខ 800-776-5746 ឬបំពេញ បែបបទស្នើសុំជំនួយ ។ សម្រាប់គោលបំណងផ្សេងៗទៀតទាំងអស់ សូមហៅទូរស័ព្ទមកលេខ 916-504-5800 (កាលីហ្វ័រនីញ៉ាខាងជើង) 213-213-8000 (កាលីហ្វ័រនីញ៉ាខាងត្បូង) ។

*Disability Rights California បានទទួលថវិកាឧបត្ថម្ភពីប្រភពផ្តល់ជំនួយមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្តល់ជំនួយ សូមទស្សនាគេហទំព័រ*
http://www.disabilityrightsca.org/ListofGrantsAndContracts.html.